# មជ្ឈមណ្ឌលឯកសារកម្ពុជា

## កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្លេងយុត្តិធម៌:   អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

## វគ្គទី៤

## ប្រធានបទ:  ការអត់ឃ្លាន  និងអំពើប្រល័យពូជសាសន៍


*ដោយ : វ៉េនឌល ឌីហ្វាល់កូ*

*ជាមួយនឹង ម៉ែន ពិចិត្រ និង លន់ ដាលីន*

*អានដោយ : ឌី ខាំបូលី និង កន ពេញសំណាង*

*សហការជាមួយបន្ទប់ថតសម្លេងរបស់ស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ*


*ខែមិថុនា ឆ្នាំ២០១៣*

*ជម្រាបសួរប្រិយមិត្តអ្នកស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទីមេត្រី! នេះគឺជាការផ្សាយវគ្គទី៤  ក្នុងចំណោមការផ្សាយទាំង១០វគ្គនៃកម្មវិធីវិទ្យុរបស់យើងខ្ញុំ  ដែលពិនិត្យទៅលើទិដ្ឋភាពប្រវត្តិសាស្ត្រ  និងច្បាប់ផ្សេងៗទាក់ទងនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥  ដល់ឆ្នាំ១៩៧៩ ។  គោលបំណងសំខាន់របស់កម្មវិធីវិទ្យុនេះ  គឺដើម្បីផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាទាំងអស់បានដឹងច្បាស់អំពីសាច់រឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលពាក់ព័ន្ធនឹងការអត់ឃ្លាន  និងជំរុញឲ្យមានការចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិ-ធម៌ ។  កម្មវិធីរបស់យើងខ្ញុំចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យតាមរយៈវិទ្យុដូចខាងក្រោម ។  វគ្គនីមួយៗនឹងត្រូវចាក់ផ្សាយចំនួនបួនដងក្នុងមួយខែ ។  រៀងរាល់ដើមខែ  យើងខ្ញុំនឹងលើកយកវគ្គថ្មីមកចាក់ផ្សាយជូនប្រិយមិត្តអ្នកស្តាប់ ។  ចំពោះប្រិយមិត្តអ្នកស្តាប់ដែលរស់នៅរាជធានីភ្នំពេញ  និងខេត្តដែលនៅជាប់នឹងរាជធានីភ្នំពេញអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំ  តាមរយៈវិទ្យុជាតិកម្ពុជា*AM918 KHz *រាជធានីភ្នំពេញ  វេលាម៉ោង  ៩ព្រឹក  និង  ម៉ោង៧និង៣០នាទីល្ងាច ។  នៅខេត្តកំពត  តាមរយៈវិទ្យុខេត្តកំពត*  FM93.25  *វេលាម៉ោង៧ព្រឹក  និង  ម៉ោង៧ល្ងាច ។  នៅខេត្តព្រះវិហារ  តាមរយៈវិទ្យុខេត្តព្រះវិហារ*  FM99  *វេលាម៉ោង៧និង៣០នាទីព្រឹក  និងម៉ោង៤រសៀល ។  នៅខេត្តបាត់ដំបងតាមរយៈវិទ្យុខេត្ត  បាត់ដំបង* FM103.25 *វេលាម៉ោង ៨ព្រឹក  និងម៉ោង៤រសៀល ។*

ការផ្សាយក្នុងវគ្គទីបួននេះ យើងខ្ញុំផ្តោតសំខាន់ទៅលើអំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាន ។ ប្រជាជនកម្ពុជាទូទៅយល់ឃើញថាឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម គឺជាអំពើប្រល័យពូជសាសន៍ ។ ហេតុដូច្នេះ យើងខ្ញុំនឹងពិភាក្សាអំពីពាក្យ "អំពើប្រល័យពូជសាសន៍" ហើយថាតើការអត់ឃ្លានដែលបានបង្កឡើងនៅក្នុងរបបខ្មែរក្រហមអាចចាត់ទុកជាអំពើប្រល័យពូជសាសន៍បានដែរឬទេ?

មុននឹងយើងចាប់ផ្តើមបទអត្ថាធិប្បាយវគ្គទីបួននេះ យើងខ្ញុំសូមជម្រាបជូនប្រិយមិត្តអ្នកស្តាប់ អំពីការវិវឌ្ឍរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ដូចដែលយើងខ្ញុំបានជម្រាបជូនប្រិយមិត្តអ្នកស្តាប់នៅក្នុងការផ្សាយវគ្គទីបីកន្លងមក អៀង សារី ដែលជាជនជាប់ចោទក្នុងសំណុំរឿង០០២ របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានស្លាប់នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ។ នួន ជា ដែលជាជនជាប់ចោទមួយរូបនៅក្នុងសំណុំរឿង០០២ បានដាក់ញត្តិមួយទៅអង្គជំនុំជម្រះសាលាដំបូង ដោយអះអាងថា ខ្លួនពុំមានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការរបស់តុលាការនោះទេ ។ នួន ជា បានលើកយកហេតុផលសុខភាពចុះខ្សោយ និងកាយសម្បទាមិនរឹងមាំ ដោយសារតែវ័យជរារបស់ខ្លួន ។ បន្ទាប់ពីបានបញ្ចប់សវនាការទៅលើកាយសម្បទារបស់ នួន ជា អង្គជំនុំជម្រះសាលាដំបូងរកឃើញថា នួន ជា មានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការតុលាការ ។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះសាលាដំបូងបានចាត់វិធានការសមរម្យមួយចំនួនដើម្បីការពារការចុះខ្សោយផ្នែកសុខភាពរបស់ជនជាប់ចោទ នួន ជា ។ ស្របពេលគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចរបស់ខ្លួនទាក់ទងទៅនឹងទំហំនៃការបំបែកសំណុំរឿង០០២ ទៅជាសំណុំរឿងតូចៗ ស្របតាមការស្នើសុំរបស់អង្គជំនុំជម្រះតុលាការកំពូល ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបន្តការកាត់សេចក្តីទៅលើបទចោទប្រកាន់ចំនួនប្រាំនៅក្នុងសំណុំរឿងទីមួយនៃសំណុំរឿង០០២ រួមមានៈ ឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងនៅពេលដែលមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ការជម្លៀសប្រជាជនកម្ពុជារាប់សែននាក់ទៅកាន់ភាគខាងជើងប្រទេសកម្ពុជា នៅចន្លោះ ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៧ ។ ប៉ុន្តែ ឧក្រិដ្ឋកម្មផ្សេងៗទៀតៗដូចជា ការដ្ឋានការងារ និងសហករណ៍របស់ខ្មែរក្រហម មន្ទីរសន្តិសុខ វាលពិឃាត ការរៀបការដោយបង្ខំ និងអំពើប្រល័យពូជសាសន៍លើជនជាតិចាម នឹងត្រូវបន្តនៅពេលក្រោយ ។ បន្ទាប់ចេញសេចក្តីសម្រេចទាំងពីរខាងលើនេះ អង្គ

ជំនុំជម្រះសាលាដំបូង បានបន្តការកាត់សេចក្តីរបស់ខ្លួនទៅលើភស្តុតាងនៅក្នុងសំណុំរឿង ដែលនៅសល់ជនជាប់ចោទចំនួនពីររូប រួមមាន ខៀវ សំផន និង នួន ជា ។

## សេចក្តីផ្តើមៈ និយមន័យនៃអំពើប្រល័យពូជសាសន៍

អំពើប្រល័យពូជសាសន៍ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៨ ពេលដែលអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ត្រូវបានធ្វើឡើង និងអនុម័តដោយអង្គការសហប្រជាជាតិ ។ ពាក្យ "ប្រល័យពូជសាសន៍" ត្រូវបានបង្កើតឡើងដោយ លោក រ៉ាហ្វែល លិមគិន (Raphael Lemkin) ដោយការផ្គុំបញ្ចូលគ្នានៃ ពាក្យ "ពូជសាសន៍" និង "សម្លាប់" ជាភាសាឡាតាំង ពាក្យ "ប្រល័យពូជសាសន៍" មានន័យថា ការសម្លាប់ដោយចេតនាទៅលើក្រុមមនុស្ស ឬពូជសាសន៍ណាមួយ ។ ពាក្យនេះ ត្រូវបានបង្កើតឡើងនៅពេលដែលគ្មានបទឧក្រិដ្ឋកម្មណាមួយអាចបង្ហាញពីការប៉ុនប៉ងរបស់ បក្សណាហ្ស៊ី-អាឡឺម៉ង់ (German Nazi Party) ក្នុងការកំចាត់ចោល ជនជាតិ ជ្វីប (Jewish) ទាំងអស់ចេញពីអឺរ៉ុប ។ ជាលទ្ធផល ច្បាប់ប្រឆាំងនឹងឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងដើម្បីដាក់ទោសចំពោះឧក្រិដ្ឋកម្មទាំងឡាយណា ដែលមានស្ថានភាពស្រដៀងគ្នានឹងឧក្រិដ្ឋកម្មដែលបានបង្កឡើងដោយ បក្សណាហ្ស៊ី-អាឡឺម៉ង់ ប្រឆាំងនឹងជនជាតិជ្វីប ។

ដើម្បីបង្ហាញថាបទឧក្រិដ្ឋមួយគឺជា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ យើងត្រូវការធាតុផ្សំចំនួនបីដូចតទៅៈ

ទី១ៈ ការប្រព្រឹត្តសកម្មភាពណាមួយក្នុងចំណោមសកម្មភាពទាំងប្រាំ រួមមាន ១)ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម ២)ការបង្កការឈឺចាប់ និងខូចខាតជាដំណំទាំងផ្នែករាងកាយ ឬផ្នែកស្មារតីដល់សមាជិកទាំងឡាយនៅក្នុងក្រុម ៣)ការបង្កឡើងដោយចេតនានូវមហន្តរាយ ឬការហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយបំផ្លិចបំផ្លាញទាំងស្រុង ឬដោយផ្នែកនៃក្រុម ៤)ការដាក់ចេញនូវវិធានការណ៍នានា ដែលបង្ការមិនឲ្យមានការបង្កកំណើតទារកនៅក្នុងក្រុម និង ៥)ការយកកូនក្មេងចេញពីសង្គមមួយ ទៅដាក់ក្នុងសង្គមរស់នៅមួយទៀតដោយបង្ខំ ។

ទី២ៈ សកម្មភាពទាំងអស់ខាងលើត្រូវតែផ្តោតពិសេសទៅលើសមាជិកទាំងអស់នៅក្នុងក្រុមណាមួយក្នុងចំណោមក្រុមជាក់លាក់ទាំងបួន រួមមាន ១)ក្រុមជាតិ ២)ជាតិពន្ធុ ៣)ពូជសាសន៍ ឬ ៤)សាសនា ។

ទី៣ៈ ជនដែលប្រព្រឹត្តសកម្មភាពដែលបានរៀបរាប់ខាងដើម ប្រព្រឹត្តសកម្មភាពទាំងនោះ ក្នុងគោលបំណងជាក់លាក់ ដើម្បីកម្ទេចក្រុមណាមួយដូចដែលបានរៀបរាប់ខាងលើ ។

ឧទាហរណ៍

ទីមួយៈ ប្រសិនបើមានប្រទេសណាមួយប៉ុនប៉ងសម្លាប់ប្រជាជនកម្ពុជា ការសម្លាប់នោះអាចចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

ទីពីរៈ ជាតិពន្ធុ គឺក្រុមមនុស្សទាំងឡាយណាដែលមានសាវតាដូចគ្នា និយាយភាសាដូចគ្នា មានប្រពៃណី និងការរស់នៅក្នុងសង្គមដូចគ្នា ។ ឧទាហរណ៍ ជនជាតិចារាយ ខ្មែរកម្ពុជាក្រោម និងជនជាតិភាគតិចផ្សេងទៀតដែលរស់នៅក្នុងប្រទេសកម្ពុជា ។ ជាមួយគ្នានេះដែរ ជាតិខ្មែរ ក៏អាចចាត់ចូលទៅក្នុងក្រុមជាតិ ដែលអាចរងគ្រោះដោយសារអំពើប្រល័យពូជសាសន៍បានដែរ ប្រសិនបើក្រុមទាំងនោះស្ថិតក្រោមការប៉ុនប៉ងបំផ្លាញពីក្រុមដទៃទៀត ។

ទីបីៈ នៅក្នុងប្រទេសកម្ពុជា ក្រុមសាសនាសំដៅទៅលើ អ្នកដែលកាន់សាសនាព្រះពុទ្ធសាសនាឥស្លាម និងជនជាតិភាគតិចដទៃទៀតដែលកាន់សាសនាផ្សេងៗ ។ ជារឿយៗ ក្រុមជាតិ ពន្ធុ និងក្រុមនៃសាសនាអាចជាក្រុមតែមួយ ។ ជាឧទាហរណ៍ បើយោងតាមនិយមន័យនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ខ្មែរឥស្លាម ត្រូវបានចាត់ចូលទៅក្នុងក្រុមសាសនាផង និងក្រុមជាតិពន្ធុផង ។

ទីបួនៈ ក្រុមពូជសាសន៍ អាចមានលក្ខណៈប្រឡំទៅនឹងក្រុមជាតិពន្ធុ ។ ប៉ុន្តែ យើងអាចកំណត់ក្រុមពូជសាសន៍បានដោយផ្អែកទៅលើបុគ្គកិកលក្ខណៈខាងក្រៅរបស់ក្រុមនោះ ដូចជា ពណ៌សម្បុរជាដើម ។ ប្រសិនបើមានក្រុមណាមួយដែលមានពណ៌សម្បុរស្បែកដូចគ្នា ត្រូវក្រុមមួយផ្សេងទៀតដែលមានពណ៌សម្បុរស្បែកខុសគ្នាប៉ុនប៉ងកម្ទេច ទង្វើនេះអាចចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ។

ជាសរុប មានតែក្រុមបួនដូចដែលបានរៀបរាប់ខាងលើប៉ុណ្ណោះ ដែលអាចជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ។ ប្រសិនបើ បុគ្គល ឬមនុស្សមួយក្រុមត្រូវបានសម្លាប់ ដោយហេតុផលនយោបាយ ឬស្ថិតនៅក្នុងក្រុមមួយដែលវណ្ណៈសង្គមរបស់ក្រុមនោះមិនត្រូវបានស្វាគមន៍ នោះឧក្រិដ្ឋកម្មដែលកើតឡើងទៅលើក្រុម ឬបុគ្គលនោះ មិនអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានទេ ។ ប៉ុន្តែ យើងអាចចាត់ទុកឧក្រិដ្ឋកម្មនោះ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

ជាលទ្ធផល យើងអាចនិយាយបានថា ឧក្រិដ្ឋកម្មមួយអាចចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បាន លុះត្រាតែ ជនដែលប្រព្រឹត្តនោះមានគោលបំណងច្បាស់លាស់ក្នុងការបំផ្លាញទាំងស្រុង ឬដោយផ្នែកនៃក្រុមមនុស្សដែលបានរៀបរាប់ខាងដើម ។ ហេតុដូច្នេះ ប្រសិនបើក្រុមមនុស្សនៃសាសនាមួយត្រូវបានសម្លាប់ ដោយសារតែជនដែលប្រព្រឹត្តនោះមានគោលបំណងច្បាស់លាស់ក្នុងការ

បំផ្លាញក្រុមនោះ ដោយហេតុផលសាសនារបស់ក្រុមនោះ ទង្វើនោះអាចចាត់ទុកថាជាអំពើប្រល័យពូជសាសន៍បាន ។

ជាក់ស្តែង ការសម្លាប់មនុស្សនៅប្រទេសរ៉្វាន់ដា ត្រូវបានគេរកឃើញថាជាអំពើប្រល័យពូជសាសន៍ ដោយសារតែក្រុមជនជាតិហ៊ូទូ បានប៉ុនប៉ងសម្លាប់ក្រុមជនជាតិទុតស៊ីទាំងអស់នៅក្នុងប្រទេសរ៉្វាន់ដា ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានដោះស្រាយនូវបញ្ហាដ៏ស្មុគស្មាញជាច្រើនទាក់ទងទៅនឹងនិយមន័យនៃអំពើប្រល័យពូជសាសន៍ នៅពេលដែលមានការសម្លាប់រង្គាលកើតឡើងនៅប្រទេសរ៉្វាន់ដាជានៅក្នុងឆ្នាំ១៩៩៤ ។

## អំពើប្រល័យពូជសាសន៍ និង ការអត់ឃ្លាន

ប្រជាជនកម្ពុជាមួយចំនួនយល់ថា ការស្លាប់ដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម គឺជាអំពើប្រល័យពូជសាសន៍ ដោយសារតែ ពាក្យ“ប្រល័យពូជសាសន៍” ត្រូវបានប្រើប្រាស់ ដើម្បីសំដៅទៅលើហេតុការណ៍ដ៏អាក្រក់ណាមួយដែលធ្វើឲ្យប្រជាជនជាច្រើននាក់ស្លាប់បាត់បង់ជីវិត ។ ប៉ុន្តែប្រជាជនកម្ពុជាអាចនឹងមានការមិនសប្បាយចិត្ត ប្រសិនបើតុលាការរកឃើញថា ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមមិនមែនជាអំពើប្រល័យពូជសាសន៍ ។ ប្រជាជនកម្ពុជាអាចយល់ថាឧក្រិដ្ឋកម្មដែលបានកើតឡើងនោះមិនមានលក្ខណៈធ្ងន់ធ្ងរ ឬមិនពិត ។

ទោះបីជាយ៉ាងណាក៏ដោយ ការបង្អត់អាហារអាចចាត់ទុកជាធាតុសំខាន់មួយនៃអំពើប្រល័យពូជសាសន៍ ។ ការបង្ហាញថា ការអត់ឃ្លានដែលបានកើតឡើង គឺជាអំពើប្រល័យពូជសាសន៍ មិនមែនផ្អែកសំខាន់ទៅលើស្ថានភាពដ៏អាក្រក់ ឬចំនួនប្រជាជនដែលបានស្លាប់ដោយសារការអត់ឃ្លាននោះទេ ។ ផ្ទុយទៅវិញ វាអាស្រ័យទៅលើកត្តាមួយចំនួន ថាតើជនដែលបង្កឲ្យមានការអត់ឃ្លាននោះ មានចេតនាបង្កឲ្យមានការអត់ឃ្លាន ដើម្បីបំផ្លាញក្រុមនៃពូជសាសន៍ ជាតិពន្ធុ ក្រុមជាតិ ឬសាសនាណាមួយដែរឬទេ?

ហេតុដូច្នេះ ចម្លើយសម្រាប់សំណួរដែលសួរថា តើការបង្អត់អាហារអាចជាអំពើប្រល័យពូជសាសន៍ដែរឬទេ គឺអាស្រ័យទៅលើចេតនារបស់ជនដែលប្រព្រឹត្តទង្វើនោះ ។ នៅក្នុងចំណុចមួយនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍បានចែងថា ឧក្រិដ្ឋកម្មមួយអាចចាត់ទុកជាអំពើប្រល័យពូជសាសន៍បាន នៅពេលដែលឧក្រិដ្ឋកម្មនោះស្តែងឡើងតាមរយៈ “ការដាក់កំហិតលក្ខខ័ណ្ឌរស់នៅ ក្នុងគោលបំណងដើម្បីបំផ្លាញទាំងស្រុង ឬដោយផ្នែកនូវ” ក្រុមជាតិ ជាតិពន្ធុ ជាតិសាសន៍ ឬសាសនា ។ ដូច្នេះប្រសិនបើក្រុមណាមួយនៃក្រុមទាំងអស់ខាងដើមត្រូវបានកំណត់ជាគោលដៅសម្រាប់ការកម្ទេច ហើយ

ការកម្ទេចនោះបង្កឡើងតាមរយៈការបង្អត់អាហារទៅលើមនុស្សភាគច្រើននៃក្រុមណាមួយ ស្ថានភាព នោះអាចចាត់ចូលទៅក្នុងបទឧក្រិដ្ឋនៃអំពើប្រល័យពូជសាសន៍បាន ។

ផ្ទុយទៅវិញ ប្រសិនបើរដ្ឋាភិបាលមួយគ្រាន់តែបានបង្កឲ្យមានលក្ខណៈរស់នៅមួយដែលលំបាក និងបានបង្កឲ្យប្រជាជនជាច្រើននាក់ស្លាប់ ប៉ុន្តែ រដ្ឋាភិបាលនោះមិនបានរៀបចំគម្រោងណាមួយ ដើម្បីកម្ទេចក្រុមណាមួយទេនោះ ករណីនេះមិនត្រូវបានចាត់ថាជាឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ទេ ។

## អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លានក្នុងរបបខ្មែរក្រហម

នៅពេលដែលយើងធ្វើការថ្លឹងថ្លែងរវាងនិយមន័យនៃអំពើប្រល័យពូជសាសន៍ និងស្ថានភាព ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម យើងអាចយល់បានថា ការអត់ឃ្លានដែលបានកើតឡើងក្នុងរបបខ្មែរក្រហមមិនមែនជាអំពើប្រល័យពូជសាសន៍នោះទេ ។

យើងលើកឡើងយ៉ាងដូច្នេះ ដោយសារតែមេដឹកនាំខ្មែរក្រហមបានបង្កើតគោលនយោបាយមួយ ដែលផ្តោតសំខាន់ទៅលើការបង្កើនផលិតកម្មកសិកម្ម និងតម្រូវការចាំបាច់របស់បដិវត្តន៍ជាងតម្រូវការរបស់ប្រជាជន ។ មេដឹកនាំខ្មែរក្រហមបានបង្ខំប្រជាជនទាំងអស់ឲ្យធ្វើការ និងហូបបាយរួមគ្នា ។ ជាងនេះទៅទៀត ការងារដែលមេដឹកនាំខ្មែរក្រហមបានដាក់ឲ្យប្រជាជនកម្ពុជាធ្វើ មានរយៈពេលច្រើនម៉ោង និងរបបអាហារដែលបានចែកឲ្យប្រជាជនមិនគ្រប់គ្រាន់ ។ កត្តាទាំងអស់នេះបានបង្កឲ្យការអត់ឃ្លានកើតឡើង និងរីករាលដាលស្ទើរគ្រប់តំបន់នៃប្រទេសប្រទេសកម្ពុជា ។

ជាមួយគ្នានឹងនេះដែរ យើងគ្មានភស្តុតាងណាមួយដែលអាចបង្ហាញថា មេដឹកនាំខ្មែរក្រហមបានបង្កើតគោលនយោបាយបង្អត់អាហារប្រជាជន ក្នុងគោលបំណងដើម្បីកម្ទេចក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយនៅក្នុងប្រទេសកម្ពុជា ដែលបណ្តាលឲ្យប្រជាជនជាច្រើននាក់ស្លាប់នោះឡើយ ។ ផ្ទុយទៅវិញ យើងមើលឃើញថាមេដឹកនាំខ្មែរក្រហមគ្រាន់តែចង់ពង្រីកការបង្កបង្កើនទិន្នផលស្រូវ និងដំណាំផ្សេងទៀតរបស់ខ្លួន ដោយមិនបានគិតពីប្រជាជនរាប់ពាន់នាក់ដែលអាចស្លាប់ដោយ-សារទង្វើរបស់ខ្លួន ។ បើទោះបីជាការមិនគិតគូរពីអាយុជីវិតរបស់ប្រជាជន គឺជារឿងមួយដ៏គួរឲ្យរន្ធត់ ប៉ុន្តែ វាក៏មិនបានបង្ហាញពីគោលបំណងនៃអំពើប្រល័យពូជសាសន៍ឡើយ ។

ហេតុផលដែលថា ការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមមិនមានការពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងប្រជាជនកម្ពុជា បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពជាក់លាក់នៃអនុ-សញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងភាពចង្អៀតនៃនិយមន័យនៃពាក្យ“អំពើប្រល័យពូជសាសន៍” ។ បើទោះបីជា ទង្វើដែលមេដឹកនាំខ្មែរក្រហមបានប្រព្រឹត្ត ដែលបានបង្កឲ្យការអត់ឃ្លានកើតឡើងនៅក្នុង

ប្រទេសកម្ពុជាក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្លួន និងបានបណ្តាលឲ្យប្រជាជនកម្ពុជារាប់សែននាក់ស្លាប់បាត់បង់ជីវិត មិនមែនជាអំពើប្រល័យពូជសាសន៍ ក៏ប៉ុន្តែ ទង្វើនោះអាចចាត់ចូលទៅក្នុងបទឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀត ដូចជា ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។ ជាងនេះទៅទៀត បើទោះបីជាអំពើប្រល័យពូជសាសន៍ត្រូវបានគេទទួលស្គាល់ថាជា «ឧក្រិដ្ឋកម្មនៃឧក្រិដ្ឋកម្ម» ប៉ុន្តែ ពុំមានចំណាត់ថ្នាក់ណាមួយត្រូវបានកំណត់តាមផ្លូវច្បាប់ ដែលថា ឧក្រិដ្ឋកម្មអន្តរជាតិណាមួយមានចំណាត់ថ្នាក់ខ្ពស់ ឬទាបជាងឧក្រិដ្ឋកម្មអន្តរជាតិណាមួយឡើយ ។ ធាតុតែមួយគត់ដែលកំណត់ថាអំពើប្រល័យពូជសាសន៍ខុសពីឧក្រិដ្ឋកម្មអន្តរជាតិដទៃផ្សេងទៀត គឺស្ថិតនៅចំណុចមួយ ថាតើជនដែលប្រព្រឹត្តអំពើនោះមានគោលបំណងជាក់លាក់ចង់កម្ទេចក្រុមណាមួយដែរឬទេ ។ ជារឿយៗ បណ្តាញផ្សព្វផ្សាយព័ត៌មានមួយចំនួន ច្រើនតែប្រើពាក្យ«ប្រល័យពូជសាសន៍» ដើម្បីពិពណ៌នាអំពីឧក្រិដ្ឋកម្មណាមួយដែលមានលក្ខណៈធ្ងន់ធ្ងរ ។

ជាសរុប បើយោងតាមផ្លូវច្បាប់ ការអត់ឃ្លានដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមប្រហែលជាមិនមែនជាអំពើប្រល័យពូជសាសន៍នោះទេ ។ ប៉ុន្តែ ការអត់ឃ្លានដែល បានកើតឡើងនោះនៅតែឆ្លុះបញ្ចាំងអំពីពេលវេលាមួយដែលប្រជាជនកម្ពុជាទទួលរងទុក្ខវេទនា និង ការឈឺចាប់ធ្ងន់ធ្ងរព្រមទាំងទទួលរងនូវការសម្លាប់រង្គាលពីសំណាក់ខ្មែរក្រហម ។ ក្នុងន័យនេះ ប្រសិនបើនៅក្រៅប្រព័ន្ធច្បាប់ ប្រជាជនភាគច្រើនអាចយល់ថា ទង្វើដែលបានកើតឡើងទាំងអស់នៅក្នុងរបបខ្មែរក្រហម គឺជាអំពើប្រល័យពូជសាសន៍ ។

*(ជាបន្តទៅនេះ យើងខ្ញុំសូមលើកយកអត្ថបទមួយក្រោមចំណងជើងថា «តើខ្មែរក្រហមទាំងអស់សុទ្ធតែអាក្រក់ឬ?» ចេញផ្សាយដោយទស្សនាវដ្តី«ស្វែងរកការពិត»របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ១០៤ ខែសីហា ឆ្នាំ២០០៨ សរសេរដោយ សោម ប៊ុនថន ។)*

# តើខ្មែរក្រហមធាំងអស់សុទ្ធតែអាក្រក់ឬ?

*ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃជ័យជម្នះជាប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យដែលបានវាយរំលំរបប លន់ នល់ ចេញពីអំណាច ។ បន្ទាប់ពីឡើងកាន់អំណាចភ្លាម ជម្រើសដំបូងនៃរបបនេះ គឺការចាត់តាំងរចនាសម្ព័ន្ធកម្មាភិបាលគ្រប់គ្រងតាមតំបន់ដើម្បីស៊ើបរកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងរបស់បក្ស ។ ដូច្នេះ ការរស់នៅរបស់ប្រជាជនត្រូវស្ថិតនៅក្នុងភាពភ័យខ្លាច និងក្រោមការឃ្លាំមើលពីអង្គការជាប្រចាំ ហើយមួយចំនួនត្រូវទទួលរងការចោទប្រកាន់ទៀតផង ។ អ្នកមានកំហុសទាំងនោះមានវាសនាមិនខុសគ្នាទេ គឺត្រូវទទួលរងការធ្វើពលកម្មជាទម្ងន់ ទារុណ-កម្មនិងការបោសសម្អាតដោយមិនរើសមុខ ដែលនេះត្រូវបានចាត់ទុកថាជារបបដ៏សាហាវឃោរឃៅសម្លាប់ប្រជាជនស្លូតត្រង់ខ្លួនឯងអស់ប្រមាណពីរលាននាក់ ។ ទោះយ៉ាងនេះក្តី ក៏អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួននៅមានទំនាក់ទំនងល្អជាមួយប្រជាជន ។ ប៉ូច ដែលធ្លាប់ធ្វើជាគណៈស្រុកក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានជួយប្រជាជនឲ្យមានសេរីភាព រួចផុតពីការចោទប្រកាន់និងដោះស្រាយអាហារឲ្យប្រជាជនបានហូបគ្រប់គ្រាន់ទៀតផង ។*


ប៉ូច

*ប៉ូច មានបងប្អូន៤នាក់ មានស្រុកកំណើតនៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ នៅឆ្នាំ១៩៦៥ ប៉ូច បានចូលបួសជាលោកសង្ឃ នៅវត្តតាំងខ្មៅ ដើម្បីរៀនធម៌និងអក្សរសាស្ត្រខ្មែរ ។ រយៈពេលពីរឆ្នាំក្រោយមក ទើប ប៉ូច លាចាកសិក្ខាបទ ហើយត្រូវបានឪពុកម្តាយរៀបចំឲ្យមានប្រពន្ធជាអ្នករស់នៅក្នុងភូមិជាមួយគ្នា ។*

**មូលដ្ឋានរំដោះ**

*នៅឆ្នាំ១៩៧១ ក្រោយពីព្រឹត្តការអំពាវនាវរបស់សម្តេចសីហនុ ឲ្យរត់ចូលព្រៃម៉ាគីដើម្បីបង្កើតចលនាតស៊ូរំដោះប្រទេសពីរបបលន់ នល់ យុវជន ប៉ូច ក៏បានស្ម័គ្រចិត្តចូលបម្រើទ័ពរណសិរ្សរួបរួមជាតិជាមួយអ្នកភូមិជាច្រើននាក់ទៀត ។ ប៉ូច ត្រូវអង្គការចាត់តាំងឲ្យមើលការខុសត្រូវប្រជាជនធ្វើស្រែចម្ការនៅអង្គភាពឃុំវាលពន់ ។ នៅឆ្នាំ១៩៧៤ ប៉ូច ត្រូវផ្លាស់ទៅអង្គភាពថ្មីមួយទៀត ដែលមានទីតាំងនៅខាងត្បូងផ្លូវជាតិលេខ៤ ស្ថិតនៅក្នុងឃុំកន្ទោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ នៅទីនេះ ប៉ូច មានភារកិច្ចអប់រំអំពីមាគ៌ាបដិវត្តន៍ចំពោះប្រជាជនដែលរត់ចេញពីភ្នំពេញមករស់នៅមូលដ្ឋាន និងដោះស្រាយជីវភាពប្រជាជននៅក្នុងអង្គភាពឃុំទាំងមូលដែលខ្វះខាតស្បៀងអាហារ ដោយទាក់ទងអ្នករស់នៅតាមមាត់ទន្លេដើម្បីទិញពោត អង្ករ ត្រី ព្រមទាំងដឹកនាំកម្លាំងប្រជាជនចុះធ្វើស្រែចម្ការទៀតផង ។ ប៉ូច រៀបរាប់ថាមានថ្ងៃមួយក្មេងស្រីម្នាក់និងនារីម្នាក់ទៀតឈ្មោះ មុំ ជាប្រជាជនរស់នៅតំបន់ខ្មាំង (លន់ នល់) ដែលធ្លាប់រាប់អានគាត់បានដើរសួររកឈ្មោះបងប្អូនចំពេលមានការប្រយុទ្ធគ្នារវាងកងទ័ព លន់ នល់ និងកងទ័ពរំដោះ(ខ្មែរក្រហម) ក៏ត្រូវកម្លាំងរំដោះស្រុកកណ្តាលស្ទឹងចាប់ខ្លួនបាននៅខាងត្បូងស្រុកអង្គស្នួល ។ បន្ទាប់មក អង្គការបានចោទអ្នកទាំងពីរថាជាខ្មាំងបង្កប់មកស៊ើបការណ៍នៅមូលដ្ឋានរំដោះដើម្បីរាយការណ៍ឲ្យកងទ័ពលន់ នល់ ។ ដោយសារមើលឃើញថាមានការធ្វើទារុណកម្មនិងវាយដំជាទម្ងន់ ប៉ូច ក៏បានទៅធានាឲ្យមានការដោះលែងនារីទាំងពីរនាក់ឲ្យមានសេរីភាពឡើងវិញ ។*

**អង្គការចាត់តាំង**

*ក្រោយកងទ័ពរំដោះទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥ អង្គការបានចាត់តាំង ប៉ូច ឲ្យធ្វើជាអនុប្រធានស្រុកស្អាង ដើម្បីគ្រប់គ្រងកម្លាំងប្រជាជនធ្វើស្រែចម្ការ ។ នៅឆ្នាំដដែលនោះ ដោយសារប្រពន្ធដើមរបស់ ប៉ូច បាត់បង់ជីវិត អង្គការក៏បានរៀបចំគាត់ឲ្យមានប្រពន្ធឈ្មោះ សល្យ ជាអ្នកស្រុកកណ្តាលស្ទឹងនិងបានកូន១ ។ រយៈពេល៧ខែក្រោយមក អង្គការបានផ្លាស់*

ប៉ូច ឲ្យមកគ្រប់គ្រងប្រជាជននៅស្រុកតាំងគោក តំបន់៤២ ភូមិភាគកណ្ដាលវិញ ។ ទោះបីជាអង្គការបានកត់ឈ្មោះប្រជាជន១៧មេសា ប្រជាជនជាប់ចោទពីបទលួចដកដំឡូង លួចអង្ករនិងអ្នកទៅធ្វើការមិនទៀងទាត់ពេលវេលាយ៉ាងណាក្ដី ក៏ ប៉ូច មិនដែលយកទោសពៃរ៍ឬរាយការណ៍ទៅថ្នាក់តំបន់ឬមជ្ឈិមដែរ ព្រោះគិតថាអ្នកទាំងអស់នេះជាអ្នកថ្មីមិនដឹងមានសមាសភាពអ្វីខ្លះ ម្យ៉ាងទៀតអាចនាំឲ្យមានការភ័ន្តច្រឡំផង ។ ដូច្នេះហើយទើបការងារដឹកនាំកម្លាំងធ្វើស្រែនៅក្នុងស្រុកតាំងគោកត្រូវធ្លាក់ទៅលើអនុលេខារបស់គាត់គ្រប់គ្រងវិញ ។ ក្រោយមក អង្គការបានណែនាំ ប៉ូច ឲ្យចុះដឹកនាំប្រជាជនធ្វើស្រែ ។ ក្នុងរយៈពេលយ៉ាងខ្លី អង្គភាពរបស់ ប៉ូច បានទទួលផលស្រូវរាប់សែនថាំងសម្រាប់ផ្គត់ផ្គង់ជីវភាពប្រជាជនដែលរស់នៅតាមសហករណ៍ក្នុងស្រុកទាំងមូល ។ ប៉ូច ធ្វើការងារបានល្អនិងមិនសូវតឹងតែងចំពោះប្រជាជនទេ ដោយបានណែនាំកម្មាភិបាលនៅថ្នាក់ក្រោមថា «អង្គការថ្នាក់លើចាត់តាំងឲ្យយើងតាមដានតែអ្នកណាដែលមានសកម្មភាពក្បត់ប្រឆាំងបក្សប៉ុណ្ណោះ មិនមែនឃើញគេខុសហើយដាក់ទោសនោះទេ» ។ ជាក់ស្ដែងនៅពេល ប៉ូច ដឹងថាឈ្លបសហករណ៍ឃុំគ្រើលទៅព័ទ្ធចាប់ខ្លួនយុវជននិងយុវនារីក្មេងៗដែលលួចបាយនិងមាន់ រំលងបានមួយថ្ងៃ គាត់បានហៅកងឈ្លបនិងប្រធានសហករណ៍មកជួបដោយនិយាយថា «មិត្តឃ្លានអាចហូបបាន រីឯក្មេងៗដែលឃ្លាន មិត្តទៅយករបស់នោះពីគ្នាហើយគំរាមកំហែងដាក់ទោសទៀត ទៅថ្ងៃមុខមិនត្រូវធ្វើដូច្នេះទេ» ។ លើសពី នេះ ប៉ូច បានប្រជុំប្រាប់ដល់ប្រជាជនថា «មិនមែនយើងជាប្រជាជន១៧មេសាបេះតែមានកំហុសនិងមានរឿងនោះទេ ធ្វើយ៉ាងណាកុំឲ្យតែនិយាយប៉ះពាល់ដល់អង្គការបានហើយ ទោះបីយើងទៅធ្វើការងារឬមិនធ្វើក្ដី» ។

## ភារកិច្ចថ្មី

នៅឆ្នាំ១៩៧៧ ប៉ូច ត្រូវអង្គការផ្លាស់ឲ្យមកគ្រប់គ្រងនៅស្រុកបារាយណ៍វិញ ។ ជារៀងរាល់ថ្ងៃ ប៉ូច ត្រូវចុះទៅត្រួតពិនិត្យការដ្ឋានជីកប្រឡាយនៅភូមិកំបើយ ឃុំចុងដូង ដែលមានប្រជាជនរាប់ម៉ឺននាក់លើកទំនប់និងជីកប្រឡាយ ។ ប៉ូច តែងតែអនុគ្រោះដល់ប្រជាជន ដោយបានកំណត់រយៈពេល១០ថ្ងៃ ត្រូវអនុញ្ញាតឲ្យប្រជាជនផ្លាស់វេនគ្នាទៅលេងផ្ទះម្ដង ព្រោះការងារធ្វើបានតាមផែនការកំណត់របស់តំបន់និងភូមិភាគហើយ ។ ថ្ងៃមួយខណៈពេលដែល ប៉ូច កំពុងបំពេញការងារនៅការដ្ឋាន អនុលេខារបស់គាត់បានហៅប្រជាជនមកចូលរួមប្រជុំដោយលើកថា «អ្នកណាដែលធ្វើឲ្យបាក់ន័ង្គល រនាស់ រទេះគោ និងអ្នកមិនទៅធ្វើពលកម្ម គឺជាខ្មាំងបំផ្លិចបំផ្លាញអង្គការ» ដែលធ្វើឲ្យប្រជាជនមានការភិតភ័យយ៉ាងខ្លាំង ។ ក្រោយពីទទួលបានដំណឹងនេះ ប៉ូច ក៏បានសម្រួលកុំឲ្យប្រជាជនភ័យខ្លាច ដោយបានហៅមនុស្សប្រមាណ៦០០នាក់ក្នុងឃុំមកពន្យល់ប្រាប់ថា «រឿងខ្វះខាត ដំឡូង បាយដោយសារយើងក្រ ចំណែកនង្គ័លបាក់បណ្ដាលមកពីយើងភ្ជួរប៉ះឈើឬថ្ម ដូច្នេះមិនមែនជាទោសកំហុសទេ» ហើយគាត់បន្តថា «មិត្តអាចដាំដំណាំនៅតាមផ្ទះបានដូចជា ពោត ដំឡូង បន្លែ ជាដើម ឬក៏ចិញ្ចឹមមាន់ ទាថែមទៀត សម្រាប់ត្រៀមហូបនៅពេលណាយើងហូបបាយនៅសហករណ៍មិនឆ្អែត» ។ យោបល់នេះធ្វើឲ្យប្រជាជនសប្បាយចិត្ត ហើយខំធ្វើការរហូតទទួលបានផលលើសយកទៅទុកនៅសហករណ៍ ហើយមួយចំនួនទៀតយកមកប្រគល់ឲ្យ ប៉ូច នៅសាលាស្រុក ។ ដោយសារ ប៉ូច ទទួលបានការគោរពរាប់អានពីប្រជាជន ទើបធ្វើឲ្យកម្មាភិបាលស្រុកមួយចំនួនមិនសូវពេញចិត្តនិងទង្វើនេះទេ ហើយក៏រាយការណ៍ទៅតំបន់និងភូមិភាគ ។ ប៉ុន្តែ ប៉ូច ធ្វើការងារបានតាមផែនការបក្ស ដូចនេះអង្គការមិនដែលចោទប្រកាន់គាត់ទេ ហើយក៏មិនបានធ្វើឲ្យប៉ះពាល់ដល់ការងាររបស់គាត់ដែរ ។ នៅពេលស្រង់ប្រវត្តិរូបសមាសភាពគ្រូបង្រៀនម្ដងៗ ប៉ូច តែងតែប្រមូលប្រជាជនមកអប់រំបំពាក់គោលជំហរនយោបាយរបស់បក្ស រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ ។ ទោះបីជាប្រជាជនធ្វើឲ្យមានកំហុសធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ ប៉ូច មិនដែលចាប់កំហុសឬរាយការណ៍ទៅថ្នាក់លើទេ ។ ជាក់ស្ដែងនៅតាមសហករណ៍កើតមានចោរលួចអង្ករ បាយ ដំឡូង សម្ភារៈរបស់អង្គការនិងលួចលាក់ធ្វើទឹកត្នោតជូរទៀត គាត់តែងតែហៅអ្នកទាំងនោះមកណែនាំជានិច្ចថា «កុំឲ្យប្រព្រឹត្តអ៊ីចឹងទៀត ចំណែកអ្នកហូបទឹកត្នោតជូរក៏ហូបចុះ ប៉ុន្តែកុំឲ្យផុំក្ងិនលើគេ» ព្រោះបើ

តំបន់ឬភូមិភាគដឹង យើងងាយស្រួលដោះស្រាយថាហូបដើម្បីគ្រាន់តែកែរោគប៉ុណ្ណោះ ។ ថ្ងៃមួយពេល ប៉ូច ឃើញប្រជាជនប្រមាណ១០នាក់នៅភូមិអូរស្វស្តី ឃុំបារាយណ៍ កំពុងធ្វើពិធីបង្សុកូលនៅក្នុងផ្ទះឲ្យសាច់ញាតិដែលស្លាប់ ប៉ូច មិនបានស្តីបន្ទោសឲ្យទេ គាត់បែរជាឈប់មើតូ ហើយប្រាប់ថា «សម័យនេះបងប្អូនដឹងហើយ ប្រយ័ត្នតែធំក្បិនធូបនិងពុងដល់ថ្នាក់លើប្រាកដជាអង្គការចោទប្រកាន់មិនខាន» ។ បន្ទាប់មក ប៉ូច បន្ថែមថា «ឥឡូវបងប្អូនទាំងអស់គ្នាធ្វើបុណ្យក៏ធ្វើចុះ ប៉ុន្តែសូមបងប្អូនបិទទ្វារធ្វើបុណ្យរួចយកខ្មោចទៅកប់ទៅ» ។ ប៉ុន្តែទោះបីជាមានការបន្ធូរបន្ថយមិនដាក់ទោសយ៉ាងនេះក្តី ក៏នៅតែមានអ្នកប្រព្រឹត្តកំហុស៣-៤នាក់ដែលត្រូវរាយការណ៍ទៅអង្គការថ្នាក់លើដែរ ។ ពេលប្រជុំរាយការណ៍ពីសកម្មភាពការងារនៅសហករណ៍ ប៉ូច តែងលើកយោបល់ឲ្យមានការបន្ធូរបន្ថយចំពោះការទាក់ទងរវាងបុរសនិងនារី ។ មួយឆ្នាំម្តង អង្គការបានកោះហៅកម្មាភិបាលនៅគ្រប់ស្រុក តំបន់ និងភូមិភាគមកប្រជុំនៅភ្នំពេញក្រោមអធិបតីភាពរបស់ នួន ជា ស្តីពីការធ្វើសហករណ៍រួម និងលើកឡើងពីគោល-ការណ៍ណែនាំរបស់មជ្ឈិមថា «ការដឹកនាំប្រៀបបានសរសៃសូត្រឬមងជំពាក់ យើងមិនអាចយកកន្ត្រៃឬកាំបិតទៅកាត់បានទេ ព្រោះអាចនាំឲ្យជំពាក់ថែមទៀត» ។ ដូច្នេះ ប៉ូច បានបញ្ជាក់ថា ការអនុវត្តនៅតំបន់ឬភូមិភាគមានលក្ខណៈផ្សេងពីគោលការណ៍ ព្រោះប្រសិនបើយើងចាត់វិធានការដាក់ទោសកំហុសនិងសម្លាប់បែបនេះ អាចធ្វើឲ្យប៉ះពាល់ដល់ក្រុមគ្រួសារសាច់ញាតិដែលមិនមានកំហុសថែមទៀត ។

**បញ្ហាថ្នាក់លើ**

នៅឆ្នាំ១៩៧៨ ប៉ូច បានចាត់តាំងនិរសារម្នាក់ឲ្យយកអង្ករទៅចែកប្រជាជនដែលខ្វះខាត ។ នៅពេលនោះ តំបន់ក៏ចុះមកណែនាំចំនួន៥ដងថា «ម៉េចបានជាមិត្តឯងមិនដកកម្មាភិបាលចាស់ចេញ?» ប៉ូច បានឆ្លើយតបវិញថា «កម្មាភិបាលទាំងអស់ខិតខំធ្វើការដឹកនាំប្រជាជនបានល្អណាស់ ហើយមិនដែលមានសកម្មភាពប្រឆាំងឬច្បាំងថ្នាក់ជាមួយអង្គការឡើយ បើមិត្តមិនជឿមិត្តអាចសួរអនុលេខានិងសមាជិកថ្នាក់ក្រោម» ។ ដោយសង្កេតឃើញថា ប៉ូច មិនបានផ្លាស់ប្តូរកម្មាភិបាលតាមការណែនាំរបស់តំបន់ អង្គការក៏ចុះមកដកយកអនុលេខាឈ្មោះ ឆន ដែលមានស្រុកកំណើតនៅស្រុកបារាយណ៍ និងឈ្មោះ ផេន ចេញ ដោយគ្រាន់តែប្រាប់ថាផ្លាស់ទៅធ្វើការនៅតំបន់ដែលមាន អឿន ជាអ្នកគ្រប់គ្រងប៉ុណ្ណោះ ។

នៅដើមឆ្នាំ១៩៧៩ ប៉ូច នាំក្រុមគ្រួសារនិងបងប្អូនរត់ទៅរស់នៅព្រៃបោះពង ស្រុកបារាយណ៍លើ ។ មួយរយៈក្រោយមក ប្រពន្ធរបស់គាត់ឈ្មោះ សល្យ និងកូនទាំង២នាក់បានស្លាប់ជាបន្តបន្ទាប់ដោយសារជំងឺគ្រុនចាញ់ ។ រស់នៅទីនោះ ប៉ូច ត្រូវបានតែងតាំងឲ្យធ្វើជាគណៈស្រុកបារាយណ៍ មានភារកិច្ចទទួលកម្លាំងតស៊ូមកពីស្រុកនានា ។ ដោយសារមានកងទ័ពរងរបួសនិងស្លាប់ដោយជំងឺច្រើន ប៉ូច បានប្រកាសថា «បើបងប្អូនណាទ្រាំនៅតស៊ូបានក៏នៅចុះ ហើយបើទ្រាំមិនបាន ឬមិនហ៊ាននៅសូមត្រឡប់ទៅផ្ទះវិញ» ។ នៅឆ្នាំ១៩៨០ ប៉ូច ត្រូវអង្គការប្តូរមកគ្រប់គ្រងកម្លាំងទ័ពប្រចាំខេត្តកំពង់ចាម និងខេត្តកំពង់ធំវិញ ។ ក្រោយមក កែ ពក បានចុះមកបញ្ជាទ័ពផ្ទាល់ ដោយតែងតាំង ពេជ្រ ជាង ជាអនុលេខា និង ប៉ូច ធ្វើជាសមាជិកចុះឃោសនាអូសទាញប្រជាជនឲ្យចុះចូលជាមួយខ្មែរក្រហមវិញ ។ នៅឆ្នាំ១៩៨៧ ប៉ូច ត្រូវពិការជើងម្ខាងដោយសារជាន់មីននៅពេលប្រយុទ្ធនៅសមរភូមិអូរអន្ទ្រង់ ឃុំខ្នារ ស្រុកជីក្រែង ខេត្តសៀមរាប ។ គាត់ត្រូវអង្គការបញ្ជូនទៅសម្រាកព្យាបាលនៅជំរំអូរត្រាវគ៧ ។ ក្រោយពីជាសះស្បើយ អង្គការបានចាត់តាំងគាត់ឲ្យមកគ្រប់គ្រងកងទ័ពខ្មែរក្រហមចំនួន៤១៧គ្រួសារ ។ ដោយសារតំបន់នេះមានការវាយប្រយុទ្ធគ្នាជាញឹកញាប់ ក្រោយមកកងទ័ពរាជរដ្ឋាភិបាលបានវាយដណ្តើមទីស្នាក់ការរបស់ ប៉ូច បាន ។ ពេលនោះ ប៉ូច បានរត់គេចខ្លួនទៅរស់ជាមួយប្រជាជនក្នុងភូមិវិញ ។ ដោយសារអំពើល្អរបស់គាត់ដែលបានធ្វើកន្លងមក ទើបអ្នកស្រុកមួយចំនួនបានលួចផ្តល់អង្ករ ត្រីងៀត និងជួយលាក់ប្រវត្តិរូបគាត់ទៀតផង ។ រហូតមកដល់សព្វថ្ងៃ នៅតែមានប្រជាជនដែលរស់នៅស្រុកបារាយណ៍និងស្រុកតាំងគោកតែងតែមកសួរសុខទុកគាត់ជានិច្ចកាល ។

**សោម ប៊ុនថន**

នេះជាចុងបញ្ចប់នៃវគ្គទីបួននៃកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌកឯកសារកម្ពុជា ដែលនិយាយពីការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ។ នៅក្នុងការផ្សាយនៃវគ្គបន្ទាប់ យើងខ្ញុំនឹងពិភាក្សាអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ផាតើ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចយកមកអនុវត្តចំពោះស្ថានភាពអត់ឃ្លានដែលបានកើតឡើងនៅក្នុងប្រទេសដទៃ ក៏ដូចជាការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមដែរឬទេ?

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រិយមិត្តអ្នកស្តាប់ដែលបានតាមដានស្តាប់ការផ្សាយរបស់យើងខ្ញុំ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណចំពោះស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ ដែលបានផ្តល់ស៊ីឌីយោថតសម្លេង ។

ប្រសិនបើប្រិយមិត្តអ្នកស្តាប់ចង់ចូលរួមផ្តល់ជាមតិយោបល់ សួរសំណួរ ឬមានចម្ងល់ផ្សេងៗនៅក្នុងកម្មវិធីសូមសរសេរជាលិខិតផ្ញើរមកកាន់ លោក ម៉ែន ពិចិត្រ អ្នករៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬប្រអប់ សំបុត្រលេខ ១១១០ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣-២១១-៨៧៥ ឬទូរសារលេខ ០២៣-២១០-៣៥៨ ។ សូមអរគុណ ។

កម្មវិធីវិទ្យុនេះឧបត្ថម្ភដោយ នាយកដ្ឋានកម្មវិធីសកលនៃការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលកម្ម របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។

កម្មវិធីវិទ្យុនេះ ចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យ តាមរយៈវិទ្យុជាតិកម្ពុជា AM918 KHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និង ម៉ោង៤រសៀល ។ វិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង៨ព្រឹក និង ម៉ោង៤រសៀល ។